# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០៦/២០០៣ កបធ.សជណ.ច

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៣

## ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
## សូមជំរាបជូន
## ឯកឧត្តម អ៊ូ ប៊ុនឡុង សមាជិកព្រឹទ្ធសភា មកពីគណបក្ស សម រង្ស៊ី

**កម្មវត្ថុ** : អំពីបណ្តឹង "សុំលុបឈ្មោះជនពុំមានល័ក្ខខ័ណ្ឌត្រឹមត្រូវគ្រប់គ្រាន់តាមមាត្រា ៥០ថ្មី និង មាត្រា ៥៤ ថ្មី នៃ ច្បាប់ស្តីពីការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ២០០៣ "

**យោង** : ពាក្យបណ្តឹងចុះថ្ងៃទី ០៤ និង ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៣

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយសជំរាបឯកឧត្តមថា សម័យប្រជុំក្រុមប្រឹក្សាធម្មនុញ្ញ ថ្ងៃទី ៧ និងថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៣ បានសម្រេចមិនទទួលយកពាក្យបណ្តឹងរបស់ឯកឧត្តមមកបើកសវនាការបានទេ ព្រោះបណ្តឹងនេះមិនបានឆ្លងកាត់ការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឱ្យស្រប នឹងវាក្យខ័ណ្ឌទី៤ នៃមាត្រា ៦៥ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលចែងថា " *គណៈកម្មាធិការជាតិរៀបចំបោះឆ្នោតត្រូវសម្រេចលើបណ្តឹងតវ៉ា ឬ ជំទាស់នោះ ដោយបើកសវនាការជាសាធារណៈក្នុងរយៈពេលប្រាំ ( ៥ ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណឹង* " ។ ទោះបីមានចំណារបញ្ជាក់ របស់ឯកឧត្តម **ទេព នីថា** អគ្គលេខាធិការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថា " *ការបដិសេធអាចប្តឹងតវ៉ាទៅ ក្រុមប្រឹក្សាធម្មនុញ្ញ តាមកំណត់ច្បាប់* " ក្នុងសំណុំលិខិតបី លើចំនួន ២៤ ក៏ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចទទួលពាក្យបណ្តឹងរបស់ឯកឧត្តមយកមកបើកសវនាការ បានដែរព្រោះវាក្យខ័ណ្ឌទី៦ នៃមាត្រា ៦៥ថ្មី បានចែងថា " *ប្រសិនបើអ្នកតវ៉ា ឬ អ្នកជំទាស់ពុំពេញចិត្តនឹងការសម្រេចរបស់គណៈកម្មាធិការ ជាតិរៀបចំការបោះឆ្នោត ជននោះ ឬ អ្នកតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៏អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលប្រាំ ( ៥ ) ថ្ងៃយ៉ាងយូរន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត* " ។

ម៉្យាងទៀតពាក្យបណ្តឹងតវ៉ា ឬ បណ្តឹងជំទាស់ទាំងឡាយត្រូវគោរពឱ្យបានម៉ត់ចត់តាមបទប្បញ្ញត្តិ នៃមាត្រា ៦៤ថ្មីនៃច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

សូមឯកឧត្តមទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- តុលាការកំពូល
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**ប៊ិន ឈិន**